ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 08 / 06 / 2016
ម៉ោង (Time/Heure): 10:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Sann Rada



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៦

**ជូនចំពោះ៖** **ភាគីទាំងអស់នៃសំណុំរឿង ០០២**

**ពី៖** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន៖** **លោក/លោកស្រីចៅក្រមទាំងអស់ និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ៖** **សេចក្តីសម្រេចលើសំណើរបស់ នួន ជា អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង និងសំណើសុំផ្តល់ឯកសារមួយដែលទាក់ទងនឹងសាក្សី ញ៉ែម អេន**

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើ អនុលោមតាមវិធាន ៨៧(៤) និង៩៣ នៃវិធានផ្ទៃក្នុង ដែលត្រូវបានផ្សព្វផ្សាយជាឯកសារចម្លង កាលពីថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ហើយមេធាវីការពារក្តី នួន ជា បានដាក់កាលពីថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៦ សុំឲ្យទទួលយកឯកសារចំនួនប្រាំបីធ្វើជាឯកសារភស្តុតាង ទាក់ទងនឹងសក្ខីកម្មរបស់សាក្សី ញ៉ែម អេន (2-TCW-919) និងទទួលយកពីសាក្សីដដែលនេះនូវសៀវភៅដែលគាត់និពន្ធដែលមានចំណងជើងថា “ញ៉ែម អេន អ្នកថតរូបខ្មែរក្រហម នៅមន្ទីរសន្តិសុខ ស-២១” (“សំណើសុំ”) (ឯកសារ E398 និងឧបសម្ព័ន្ធ ១ ដល់៨) ធ្វើជាឯកសារភស្តុតាង។ នៅថ្ងៃទី ១៩ ខែ មេសា ឆ្នាំ២០១៦ អង្គជំនុំជម្រះបានស្តាប់សារណាផ្ទាល់មាត់របស់មេធាវីការពារក្តី នួន ជា ព្រមទាំងចម្លើយតបរបស់ភាគីដទៃទៀត។ នៅថ្ងៃដដែលនោះ អង្គជំនុំជម្រះបានសម្រេចយល់ព្រមតាមសំណើមួយផ្នែក ដោយទទួលយកឯកសារចំនួនប្រាំពីរ ក្នុងចំណោម

ឯកសារទាំងប្រាំបីដែលបានស្នើសុំ (ប្រតិចារឹកថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៦ ទំព័រ ៩៤)។ នៅថ្ងៃទី ២០ ខែ មេសា ឆ្នាំ២០១៦ អង្គជំនុំជម្រះក៏បានទទួលយកសៀវភៅរបស់ ញ៉ែម អេន (សេចក្តីព្រាងប្រតិចារឹកថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១៦ ទំព័រ ១២) ។ អង្គជំនុំជម្រះសូមផ្តល់សំអាងហេតុសម្រាប់សេចក្តីសម្រេចរបស់ខ្លួន។

២. ឯកសារទីមួយ គឺជារបាយការណ៍ស្តីពីការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួសរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត (“OCIJ”) ទាក់ទងនឹងការសន្ទនា រវាងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតជាមួយ ញ៉ែម អេន (ឯកសារ E398.1.1)។ ឯកសារទីពីរ គឺជាអត្ថបទសារព័ត៌មាន Phnom Penh Post ទាក់ទងនឹងប្រភពរូបថតរបស់អ្នកទោសនៅមន្ទីរសន្តិសុខ ស-២១ ដែលបានរកឃើញនៅមន្ទីរសន្តិសុខ ស-២១ និងកម្មសិទ្ធិទៅលើរូបថតទាំងអស់នេះ (ឯកសារ E398.1.2) ។ ឯកសារទីបី គឺជាអត្ថបទសារព័ត៌មានមួយទៀតរបស់សារព័ត៌មាន Phnom Penh Post ទាក់ទងនឹងការប៉ុនប៉ងរបស់ ញ៉ែម អេន ក្នុងការបង្កើតសារមន្ទីរមួយ ដើម្បីដាក់វត្ថុអនុស្សាវរីយ៍នានាដែលគាត់ប្រមូលបានពីរបបខ្មែរក្រហម (ឯកសារ E398.1.3) ។ ឯកសារទីបួន គឺជាអត្ថបទរបស់គេហទំព័រសាកលវិទ្យាល័យ Minnesota ទាក់ទងនឹងប្រភពនៃរូបថតដែលបានរកឃើញនៅមន្ទីរសន្តិសុខ ស-២១ (ឯកសារ E398.1.4) ។ ឯកសារទីប្រាំ គឺ ជាអត្ថបទសារព័ត៌មាន Cambodian Daily ស្តីពីការហាមឃាត់ ញ៉ែម អេន មិនឱ្យលក់សៀវភៅរបស់គាត់នៅបរិវេណសារមន្ទីរទួលស្លែង (ឯកសារ E398.1.5) ។ ឯកសារទីប្រាំមួយ ដល់ ទីប្រាំបី គឺជារូបថត ដែលក្នុងនោះរួមមាន រូបថត ៣ សន្លឹករបស់ ញ៉ែម អេន នៅពេលគាត់នៅជាកម្មាភិបាលខ្មែរក្រហម (ឯកសារ E398.1.6) រូបថត១ សន្លឹករបស់មនុស្ស ៣ នាក់ ដែលជាកម្មាភិបាលខ្មែរក្រហមនៅមន្ទីរសន្តិសុខ ស-២១ (ឯកសារ E398.1.7) និងរូបថតមួយសន្លឹករបស់អ្នកជាប់ឃុំនៅមន្ទីរសន្តិសុខ ស-២១ ដដែល (ឯកសារ E398.1.7) ។ មេធាវីការពារក្តី នួន ជា លើកឡើងថា ឯកសារទីមួយ ទីបួន និង ទីប្រាំ អាចរកបានក្រោយឆ្នាំ ២០១១ ហេតុដូច្នេះហើយ សំណើរបស់ពួកគាត់ សុំឱ្យទទួលយកឯកសារទាំងអស់នេះ គឺបានទាន់ពេលវេលា។ ទោះបីជាឧបសម្ព័ន្ធ ២, ៣, ៦, ៧ និង ៨ អាចរកបានមុនពេលចាប់ផ្តើមសវនាការក៏ដោយ តែមេធាវីការពារក្តី នួន ជា បានលើកឡើងថាពួកគេមិនគិតឃើញជាមុនថា ត្រូវប្រើប្រាស់ឯកសារទាំងអស់នេះឡើយ ដោយសារតែខ្លួនមិនបានដឹងថា ញ៉ែម អេន នឹងមកបង្ហាញខ្លួនជាសាក្សីនោះទេ ហើយទើបតែដឹងក្នុងពេលថ្មីៗនេះ

ប៉ុណ្ណោះ។លើសពីនេះទៀត មេធាវីការពារក្តី នួន ជា បានលើកឡើងថា ឯកសារដែលបានស្នើសុំទាំងអស់ គឺមានការជាប់ពាក់ព័ន្ធជាមួយនឹងសក្ខីកម្មរបស់ ញ៉ែម អេន និងភាពអាចជឿជាក់បានរបស់គាត់ ហើយឯកសារទាំងអស់នេះ គឺមានការជាប់ទាក់ទងគ្នាយ៉ាងជិតស្និទ្ធជាមួយនឹងសម្ភារៈដែលមានស្រាប់នៅចំពោះមុខអង្គជំនុំជម្រះ ដូចជា កំណត់ហេតុនៃការស្តាប់ចម្លើយរបស់ ញ៉ែម អេន ជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេត និងរូបថតផងទៃទៀតនៅមន្ទីរសន្តិសុខស-២១ ដែលគាត់ជាអ្នកថត (ឯកសារ E398 ពីកថាខណ្ឌ១៧ ដល់កថាខណ្ឌ១៩)។

៣. មេធាវីការពារក្តី នួន ជា ក៏បានស្នើឱ្យអង្គជំនុំជម្រះទទួលយកសៀវភៅរបស់ ញ៉ែម អេន ដើម្បីឱ្យភាគីនានាអាចពិនិត្យមើលទៅលើខ្លឹមសារសៀវភៅនេះ។ មេធាវីការពារក្តីលើកឡើងថា សៀវភៅនេះ គឺដូចជាចម្លើយរបស់សាក្សីនេះដែរ ហើយថា សៀវភៅនេះទាក់ទងនឹងប្រធានបទសវនាការ ដែលគាត់គ្រោងនឹងមកផ្តល់សក្ខីកម្ម (ឯកសារ E398 កថាខណ្ឌ ២០)។

៤. សហព្រះរាជអាជ្ញាមិនបានជំទាស់ទៅនឹងឯកសារណាមួយឡើយ។ ប៉ុន្តែ សហព្រះរាជអាជ្ញាបានលើកឡើងថា ឯកសារទី៤ មិនមានតម្លៃជាភស្តុតាងខ្លាំងនោះទេ ហើយថា ប្រហែលជាមានរូបថតចំនួនមួយពាន់សន្លឹក ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានរកឃើញ ហើយនៅពេលបច្ចុប្បន្ននេះ វាជាកម្មវត្ថុនៃសំណើ (ឯកសារ E394) របស់សហព្រះរាជអាជ្ញា ដែលអាចផ្តល់ព័ត៌មានបន្ថែមទៀតអំពីប្រភពនៃរូបថតដែលបានថតនៅមន្ទីរសន្តិសុខ ស-២១(ប្រតិចារឹកថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៦ ទំព័រ ៦២ ដល់៦៣) ។ សហព្រះរាជអាជ្ញាក៏បានកត់សម្គាល់បន្ថែមទៀតដែរថា បុគ្គលនៅក្នុងរូបថតក្នុងឯកសារទី៨ មិនប្រាកដថាបានជាប់ឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខ ស-២១ ឬយ៉ាងណាទេ (ប្រតិចារឹកថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៦ ទំព័រ ៦៤)។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមិនបានជំទាស់ទៅនឹងការទទួលយកឯកសារដែលបានស្នើសុំនោះទេ (ប្រតិចារឹកថ្ងៃទី១៩ ខែ មេសា ឆ្នាំ ២០១៦ ទំព័រ ៦៦, សេចក្តីព្រាងប្រតិចារឹកថ្ងៃទី២០ ខែ មេសា ឆ្នាំ ២០១៦ ទំព័រ ១២)។ មេធាវីការពារក្តី ខៀវ សំផន មិនបានជំទាស់ទៅនឹងឯកសារដែលបានស្នើសុំនោះឡើយ។

៥. យោងតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង នៅគ្រប់ដំណាក់កាលនៃការជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូងអាចទទួលយករាល់ភស្តុតាងដែលអាចនាំទៅដល់ការស្វែងរកការពិត ប្រសិនបើភស្តុតាងនោះ បានបំពេញតាមបទដ្ឋានបឋមនៃភាពពាក់ព័ន្ធ ភាពអាចជឿជាក់បាន និង

យថាភាព ដូចបានតម្រូវតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះ កំណត់អំពីខ្លឹមសារនៃសំណើសុំដើម្បីទទួលយកភស្តុតាងថ្មីដោយផ្អែកតាមលក្ខណៈវិនិច្ឆ័យនៃវិធាន៨៧ (៣) នៃវិធានផ្ទៃក្នុង ។ វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងក៏តម្រូវផងដែរថា ភាគីណាដែលស្នើសុំឱ្យទទួលយកភស្តុតាងថ្មី ត្រូវស្នើសុំតាមរយៈសំណើសុំដែលមានសំអាងហេតុ។ ភាគីដែលស្នើសុំត្រូវធ្វើឱ្យអង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ភស្តុតាងដែលបានស្នើឡើង មិនអាចរកបាននៅមុនពេលបើកសវនាការ ឬ មិនអាចស្វែងរកឃើញទោះបីជាខិតខំព្យាយាមយ៉ាងណាក្តី ។ ទោះជាយ៉ាងនេះក្តី នៅក្នុងករណីខ្លះ អង្គជំនុំជម្រះបានទទួលយកភស្តុតាង ដែលមិនបានបំពេញសព្វគ្រប់ទាំងអស់តាមលក្ខណៈវិនិច្ឆ័យនេះឡើយ រួមមាន ក្នុងករណីដែលភស្តុតាងពាក់ព័ន្ធជិតស្និទ្ធជាមួយនឹងសម្ភារៈដែលមានស្រាប់នៅចំពោះមុខអង្គជំនុំជម្រះ និងក្នុងករណីដែលប្រយោជន៍យុត្តិធម៌តម្រូវឱ្យវាយតម្លៃរួមគ្នាជាមួយប្រភព និងនៅក្នុងករណីដែលឯកសារត្រូវបានស្នើឡើង គឺជាឯកសារដោះបន្ទុក និងតម្រូវឱ្យមានការវាយតម្លៃ ដើម្បីជៀសវាងការមានកំហុសផ្នែកយុត្តិធម៌ (ឯកសារ E276/2, កថាខណ្ឌ ២ យោងទៅរកឯកសារ E190 និងឯកសារ E172/24/5/1, E260, កថាខណ្ឌ៥) ។

៦. ទោះបីជាឯកសារទីមួយ, ទីបួន និងទីប្រាំ មិនអាចរកបាននៅមុនពេលចាប់ផ្តើមសវនាការក្នុងឆ្នាំ ២០១១ ក៏ដោយ ក៏ប៉ុន្តែ អង្គជំនុំជម្រះយល់ឃើញថា សំណើសុំឱ្យទទួលយកឯកសារនេះមានភាពយឺតយ៉ាវ។ ឯកសារទាំងអស់នេះត្រូវបានចេញផ្សាយក្នុងចន្លោះ ខែ ឧសភា ឆ្នាំ ២០១៤ ដល់ ខែ មីនា ឆ្នាំ ២០១៥។ ភាគីទាំងអស់ត្រូវខិតខំព្យាយាម និងត្រូវស្នើសុំឱ្យទទួលយកឯកសារឱ្យបានទាន់ពេលវេលា គឺឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន បន្ទាប់ពីបានដឹងអំពីសម្ភារៈដែលខ្លួនចង់ស្នើសុំឱ្យទទួលយក (ឯកសារ E344/1, កថាខណ្ឌ ៤, ឯកសារ E323/1, កថាខណ្ឌ ៤) ។ អង្គជំនុំជម្រះមិនជឿថា ការពន្យារពេលក្នុងការស្នើសុំឱ្យទទួលយកឯកសារទាំងអស់នេះ អាចជាប់ទាក់ទងជាមួយនឹងការជ្រើសរើសសាក្សីរូបនេះ ក្នុងខែមីនា ឆ្នាំ ២០១៦ ឡើយ (ឯកសារ E398, កថាខណ្ឌ ១៧)។ សាក្សីនេះត្រូវបានស្នើឡើងដោយមេធាវីការពារក្តី នួន ជា ក្នុងសំណុំរឿង ០០២/០២ នាឆ្នាំ ២០១៤ (ឯកសារ E305/4.2, ទំព័រ ២៧ ដល់២៨)។ ដូចគ្នានេះដែរ ការទទួលយកសៀវភៅរបស់ ញ៉ែម អេន ដែលត្រូវបានបោះពុម្ពផ្សាយក្នុងឆ្នាំ ២០១៤ គួរត្រូវបានស្នើសុំតាំងតែពីពេលមុនមកម្លេះ។ អង្គជំនុំជម្រះកត់សម្គាល់ថា សៀវភៅនេះត្រូវបានលើកឡើងនៅក្នុងឯកសារទីប្រាំ ដែលត្រូវបានបោះពុម្ព

ផ្សាយក្នុងខែ មីនា ឆ្នាំ២០១៥ ហើយក៏បានផ្តល់ព័ត៌មានដល់ភាគីទាំងអស់ឲ្យបានដឹងពីអត្ថិភាពរបស់វាផងដែរ។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា សំណើនេះមានភាពយឺតយ៉ាវសម្រាប់ឯកសារទាំងអស់នេះ។

៧. អង្គជំនុំជម្រះកត់សម្គាល់ថា សំណើសុំទាក់ទងនឹងឯកសារដទៃទៀត ក៏មានភាពយឺតយ៉ាវផងដែរ។ ឯកសារទីពីរ និងឯកសារទីបី ត្រូវបានចុះកាលបរិច្ឆេទនៅខែ សីហា ឆ្នាំ ២០០២ និងខែមិថុនា ឆ្នាំ ២០១០។ រូបថតរបស់ ញ៉ែម អេន នៅក្នុងឯកសារទីប្រាំមួយ អាចរកបាននៅក្នុងសំណុំរឿងតាំងពីឆ្នាំ ២០០៨ មក។ រូបថតទាំងអស់នេះ ត្រូវបានដាក់ចូលក្នុងសំណុំរឿងក្នុងដំណាក់កាលស៊ើបអង្កេតក្នុងសំណុំរឿង ០០២ ហើយនៅពេលនោះត្រូវបានកំណត់លេខឯកសារ D108/3/15.1 ដែលលេខនេះនៅតែអាចមើលឃើញនៅលើរូបថតនៅឡើយ។ ទោះបីជាឯកសារទីប្រាំពីរ មិនមានចុះកាលបរិច្ឆេទក៏ដោយ មេធាវីការពារក្តី នួន ជា ទទួលស្គាល់ថារូបថតនេះអាចរកបានតាំងពីមុនចាប់ផ្តើមសវនាការ។ ឯកសារទីប្រាំបី ដែលជាផ្នែកមួយនៃសំណុំរឿងក្នុងសំណុំរឿង ០០១ ត្រូវបានផ្សព្វផ្សាយជាសាធារណៈ ក្នុងខែ កញ្ញា ឆ្នាំ ២០១២។ ដូចដែលបានកត់សម្គាល់ខាងលើ អង្គជំនុំជម្រះមិនជឿថា មេធាវីការពារក្តីមិនបានគិតទុកជាមុនថា ត្រូវប្រើប្រាស់ឯកសារទាំងអស់នេះ ដោយសារតែខ្លួនមិនបានដឹងថា ញ៉ែម អេន នឹងត្រូវមកបង្ហាញខ្លួនជាសាក្សីឡើយ ហើយថា ខ្លួនទើបតែបានដឹងក្នុងពេលថ្មីៗនេះនោះទេ (ឯកសារ E398 កថាខណ្ឌ១៧) ។

៨. ទោះបីជាសំណើនេះមានភាពយឺតយ៉ាវក៏ដោយ តែអង្គជំនុំជម្រះយល់ឃើញថា ដើម្បីជាប្រយោជន៍យុត្តិធម៌ ត្រូវទទួលយកឯកសារទីមួយ ទីពីរ ទីបី ទីបួន ទីប្រាំមួយ ទីប្រាំពីរ និងឯកសារទីប្រាំបី។ ឯកសារទាំងអស់នេះមានភាពពាក់ព័ន្ធ និងអាចជឿជាក់បាន ហើយទាក់ទងជិតស្និទ្ធជាមួយនឹងសម្ភារៈដទៃទៀតដែលមាននៅក្នុងសំណុំរឿង រួមទាំងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម អេន ដោយការិយាល័យសហចៅក្រមស៊ើបអង្កេត (ឯកសារ E3/68, ឯកសារ E3/9532) ។ អង្គជំនុំជម្រះយល់ឃើញថា ឯកសារទីមួយ និងឯកសារទីបី ពាក់ព័ន្ធនឹងហេតុផលដែលសាក្សី ញ៉ែម អេន មកផ្តល់សក្ខីកម្ម និងភាពអាចជឿជាក់បានរបស់គាត់។ ហេតុដូច្នេះ ការប្រើប្រាស់ឯកសារទាំងពីរនេះដើម្បីសួរដេញដោលសាក្សី អាចជួយដល់ការស្វែងរកការពិត។ ចំពោះឯកសារទីពីរ និងឯកសារទីបួន អង្គជំនុំជម្រះយល់ឃើញថា ឯកសារទាំងអស់នេះផ្តល់ភស្តុតាងពាក់ព័ន្ធស្តីពីប្រភពនៃរូបថតដែលបានថតនៅ

មន្ទីរសន្តិសុខ ស-២១ ។ រូបថតនៅក្នុងឯកសារទីប្រាំមួយជារបស់ ញ៉ែម អេន ដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា រូបថតនេះពាក់ព័ន្ធចំពោះភាគីក្នុងការប្រើប្រាស់រូបថតទាំងនេះ នៅពេលសួរដេញដោលសាក្សីរូបនេះ។ រូបថតក្នុងឯកសារទីប្រាំពីរ និងឯកសារទីប្រាំបី ហាក់ដូចជាថតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ រូបថតទាំងអស់នេះពាក់ព័ន្ធខ្លាំងជាមួយនឹងរូបថតដទៃទៀត ដែលត្រូវបានរកឃើញនៅមន្ទីរសន្តិសុខ ស-២១ ហើយដែលត្រូវបានទទួលយកធ្វើជាភស្តុតាងក្នុងសំណុំរឿង ០០២ រួចហើយ។ ការកត់សម្គាល់របស់សហព្រះរាជអាជ្ញា គឺមានភាពពាក់ព័ន្ធជាមួយនឹងតម្លៃជាភស្តុតាងរបស់រូបថត មិនមែនពាក់ព័ន្ធនឹងភាពអាចទទួលយកបាននោះឡើយ។ ផ្អែកលើចំណុចខាងលើនេះ ឯកសារទាំងអស់នេះអាចជួយដល់ការស្វែងរកការពិត ដូច្នេះ ឯកសារទាំងអស់នេះត្រូវបានទទួលយក។

៩. ចំពោះសៀវភៅរបស់ ញ៉ែម អេន អង្គជំនុំជម្រះកត់សម្គាល់ថា ក្នុងកិច្ចដំណើរការនីតិវិធីកាលពីថ្ងៃទី២០ ខែមេសា ឆ្នាំ ២០១៦ សាក្សីបានផ្តល់សៀវភៅដល់ភាគីទាំងអស់។ ហេតុដូច្នេះ សំណើសុំសៀវភៅមួយក្បាលនេះ គឺមិនមានប្រយោជន៍ទេ។ សៀវភៅនេះបានរៀបរាប់ពីបទពិសោធន៍របស់ ញ៉ែម អេន ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ រួមទាំងក្នុងពេលដែលគាត់ធ្វើការនៅមន្ទីរសន្តិសុខ ស-២១ ក្នុងឆ្នាំ ១៩៧៦។ អង្គជំនុំជម្រះយល់ឃើញថា សៀវភៅនេះពាក់ព័ន្ធជាមួយនឹងសំណុំរឿង០០២/០២ ជាពិសេសប្រធានបទសវនាការស្តីពីមន្ទីរសន្តិសុខ ស-២១ ហើយឯកសារនេះពាក់ព័ន្ធខ្លាំងជាមួយនឹងសម្ភារៈដែលមានរួចហើយ នៅចំពោះមុខអង្គជំនុំជម្រះ ជាមួយនឹងសាក្សីរូបនេះ។ ឯកសារនេះអាចជួយដល់ការស្វែងរកការពិត។ ហេតុដូច្នេះ អង្គជំនុំជម្រះទទួលយកសៀវភៅនេះធ្វើជាឯកសារភស្តុតាង។

១០. អង្គជំនុំជម្រះបដិសេធសំណើសុំឱ្យទទួលយកឯកសារទីប្រាំ ។ អង្គជំនុំជម្រះយល់ឃើញថា អត្ថបទនេះមិនទាក់ទងផ្ទាល់ជាមួយនឹងប្រធានបទសវនាការដែល ញ៉ែម អេន គ្រោងនឹងមកផ្តល់សក្ខីកម្មនោះទេ។ លើសពីនេះទៀត ដោយសារតែមេធាវីការពារក្តី នួន ជា យល់ឃើញថា ឯកសារនេះពាក់ព័ន្ធទៅនឹងភាពអាចជឿទុកចិត្តបានរបស់ ញ៉ែម អេន ។ ហេតុដូច្នេះ សាក្សីរូបនេះអាចត្រូវបានសួរដេញដោលអំពីភាពអាចជឿទុកចិត្តបានរបស់គាត់ ក្នុងអំឡុងពេលផ្តល់សក្ខីកម្ម។

១១. ផ្អែកទៅលើសំអាងហេតុខាងលើ សំណើសុំត្រូវបានយល់ព្រមតាម ចំពោះឯកសារទីមួយ ទីពីរ ទីបី ទីបួន ទីប្រាំមួយ ទីប្រាំពីរ ទីប្រាំបី និងសៀវភៅដែលមានចំណងជើងថា "ញ៉ែម អេន អ្នកថតរូបខ្មែរក្រហមនៅមន្ទីរសន្តិសុខ ស-២១" ។ អង្គជំនុំជម្រះសាលាដំបូងកំណត់លេខឯកសារ E3 សម្រាប់ឯកសារទាំងអស់នេះ ដូចបានបញ្ជាក់ក្នុងឧបសម្ព័ន្ធដែលភ្ជាប់មកជាមួយ។ អង្គជំនុំជម្រះសម្រេចបដិសេធសំណើសុំឱ្យទទួលយកឯកសារទីប្រាំ។

១២. ឯកសារនេះ ជាចម្លើយតបផ្លូវការរបស់អង្គជំនុំជម្រះសាលាដំបូងចំពោះសំណើសុំ E398 ។